ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០១៥......សហវ

**សារាចរណែនាំ**

**ស្តីពី**

**ការអនុវត្តការប្រើប្រាស់តែមប្រើអាករប្រភេទថ្មីសម្រាប់បង់អាករពិសេសលើផលិតផលបារី**

អនុលោមតាមប្រកាសលេខ ១៤៨០ សហវ.ប្រក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការប្រើប្រាស់តែមប្រើអាករសម្រាប់បង់អាករពិសេសលើផលិតផលបារី តែមប្រើអាករត្រូវបានកែសម្រួលនិងធ្វើឱ្យប្រសើរឡើងទាំងគុណភាពនិងសុវត្ថិភាពខ្ពស់ ក្នុងគោលបំណងដើម្បីពង្រឹងការគ្រប់គ្រងនិងប្រមូលចំណូលពន្ធគ្រប់ប្រភេទ ក៏ដូចជាការទប់ស្កាត់ការគេចវេស និងបន្លំពន្ធ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំដូចខាងក្រោម៖

១. សហគ្រាសផលិតនិងនាំចូលផលិតផលបារី ត្រូវមកទទួលតែមប្រើអាករប្រភេទថ្មីត្រឹមថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៧ ដើម្បីយកទៅបិទសាកល្បង (Testing) ហើយត្រូវជូនដំណឹងមកអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អំពីលទ្ធផលនៃការសាកល្បងនេះ ត្រឹមថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧

២. ចាប់ពីថ្ងៃចេញសារាចរនេះ សហគ្រាសផលិតនិងនាំចូលផលិតផលបារីត្រូវស្នើមកអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នូវតម្រូវការតែមប្រើអាករ ដោយភ្ជាប់ជាមួយនូវផែនការផលិតនិងនាំចូលផលិតផលបារីនៃឆ្នាំបន្ទាប់តាមខែនីមួយៗ ដោយភ្ជាប់មកជាមួយនូវប្រាក់តម្កល់សម្រាប់ជាការធានាឱ្យបានជាមុន

៣. ចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ តទៅ សហគ្រាសផលិតនិងនាំចូលផលិតផលបារី ត្រូវមកទិញ និងចាប់ផ្តើមប្រើប្រាស់តែមប្រើអាករប្រភេទថ្មី

៤. ចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៧ តទៅ មិនអនុញ្ញាតឱ្យប្រើប្រាស់តែមប្រើអាករប្រភេទចាស់បិទលើផលិតផលបារីផលិតក្នុងស្រុក ឬនាំចូលទៀតឡើយ

៥. ចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៧ តទៅ មិនអនុញ្ញាតឱ្យមានចរាចរចែកចាយ ឬលក់ផលិតផលបារីដែលបិទតែមប្រើអាករប្រភេទចាស់នៅលើទីផ្សារទៀតឡើយ។

ទទួលបានសារាចរនេះ អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋាននានាក្រោមចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ម្ចាស់សហគ្រាសផលិត ឬនាំចូលផលិតផលបារី ត្រូវសហការអនុវត្តឱ្យមានប្រសិទ្ធភាពនិងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ខែ ធ្នូ ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ
- សភាពាណិជ្ជកម្មកម្ពុជា
- ឯកសារ កាលប្បវត្តិ